# ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល**

**ជាតិ សាសនា ព្រះមហាក្សត្រ**

********

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៦៦

ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០១

សាលដីកា

លេខ : ១១៦

ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០០១

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០១

ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម ឌិត មុន្នី ជាប្រធាន

២- លោក ជីវ កេង ជាចៅក្រមរបាយការណ៍

៣- លោក ឈឹម ស៊ីផល ជាចៅក្រម

៤- លោក ប្រាក់ គឹមសាន ជាចៅក្រម

៥- លោក សោម សិរីវុឌ្ឍ ជាចៅក្រម

ក្រឡាបញ្ជី

លោក អ៊ុំ សុផុន

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកា លេខ ៤៩ " ឈ " ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០០០ នៃ សំណុំរឿងរដ្ឋប្បវេណី លេខ ៤៩៣ ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ ។

- រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះថងសិទ្ធិ លីឡាប្រាក់ថាក់ (Tongstit lelapratak) ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិថៃ មុខរបរ តំណាងឱ្យក្រុមហ៊ុនពិភពពាណិជ្ជ ទីលំនៅ ផ្ទះលេខ ៣៣ វិថី សម្តេចចក្រីប៉ុន ផ្លូវលេខ ២០៨ សង្កាត់បឹងរាំង ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។

មានមេធាវី លោកស្រី កែវ គឹមសាន

- និងចុងបណ្តឹងសាទុក្ខឈ្មោះ វ៉ាន់ ស៊ូអៀង ភេទប្រុស អាយុ ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរ ពាណិជ្ជករ ទីលំនៅ ផ្ទះលេខ ៩០ ផ្លូវព្រះសីហនុ សង្កាត់បឹងកេងកង I ខណ្ឌចំការមន ក្រុងភ្នំពេញ ។

មានមេធាវី លោក ជូ ចាន់ដារ៉ា

- អំពីវិវាទ : សុំប្តឹងមោឃៈភាពកិច្ចសន្យា

បានឃើញបណ្តឹងសាទុក្ខលេខ ២៣ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១ របស់ លោកស្រី កែវ គឹមសាន ប្តឹងមិនសុខចិត្ត ពីសាលដីកា រដ្ឋប្បវេណី លេខ ៤៩ " ឈ " ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ៦៦ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០១ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ១៨-៥-១៩៩៨ របស់ដើមចោទ លោក វ៉ាន់ ស៊ូអៀង ប្តឹងសុំមោឃៈភាពកិច្ចសន្យារវាងក្រុមហ៊ុនពិភពពាណិជ្ជកម្ពុជា និង ខ្លួន និងទាមទារប្រាក់ USD 97500 ( កៅសិបប្រាំពីរពាន់ប្រាំរយដុល្លារអាមេរិកគត់) ពីឈ្មោះ ថងសិទ្ធិ លីឡាប្រាក់ថាក់ (Tongstit lelapratak) ជាប្រធានក្រុមហ៊ុនពិភពពាណិជ្ជកម្ពុជា និង ឈ្មោះ ឡាយ គីមថង ( Lai kim Tong ) ជាប្រធានចាត់ការទូទៅ នៃក្រុមហ៊ុនពិភពពាណិជ្ជកម្ពុជា។ ការរកស៊ីរួមគ្នានេះ ដែលមានលោក ថងសិទ្ធិ លីឡាប្រាក់ថាក់ ហៅកាត់ថា ភាគី ( ក ) បានចុះកិច្ចសន្យារកស៊ីរួមគ្នាជាមួយខ្លួន ( វ៉ាន់ ស៊ូអៀង ) ហៅកាត់ថា ភាគី " ខ "

ភាគី " ខ " បានចេញដើមទុនដូចជា :

១- បានប្រគល់ប្រាក់កក់ទៅឱ្យភាគី ( ក ) ចំនួន ៦០.០០០ដុល្លារអាមេរិក គឺលើកទី១ ថ្ងៃទី ៨-៦-១៩៩៧ ចំនួន ៣០.០០០ដុល្លារអាមេរិក និង លើកទី២ ថ្ងៃទី ២៥-៦-១៩៩៧ ចំនួន ៣០.០០០-ដុល្លារអាមេរិក ។

២- បានឱ្យប្រាក់ថ្លៃជួសជុលទៅភាគី ( ក ) ពីរលើកចំនួន ១២.៥០០ដុល្លារអាមេរិក គឺ :

- លើកទី ១ : ថ្ងៃទី ២២-១០-៩៧ ចំនួន ៨០០០ដុល្លារអាមេរិក
- លើកទី២ : ថ្ងៃទី ០៨-១២-៩៧ ចំនួន ៤៥០០ដុល្លារអាមេរិក

៣- ដើម្បីឱ្យភាគី ( ខ ) នាំគ្រឿងចក្រចូលក្នុងទីតាំងធ្វើអាជីវកម្ម បានភាគី ( ក ) ឱ្យភាគី ( ខ ) ជួសជុលកែលំអតាមតំរូវការអស់ប្រាក់ចំនួន ២០.០០០ដុល្លារអាមេរិក ។

៤- ភាគី ( ក ) បានឱ្យភាគី ( ខ ) ចេញថ្លៃឈ្នួលទីតាំងសំរាប់ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ក្នុង ១ខែ ចំនួន ៥.០០០ដុល្លារអាមេរិក ។

សរុបទាំងអស់ចំនួន ៩៧.៥០០ដុល្លារអាមេរិក ។

រាល់ការប្រគល់ទៅឱ្យភាគី ( ក ) គឺលោក ឡាយ គីមថង ជាប្រធានចាត់ការទូទៅ នៃ ក្រុមហ៊ុនពិភពពាណិជ្ជកម្ពុជា ជាអ្នកទទួល ។

តាមពាក្យបណ្តឹងតប ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៨ របស់អ្នកស្រី កែវ គីមសាន ជាមេធាវីតំណាងឱ្យឈ្មោះ ថងសិទ្ធិ លីឡាប្រាក់ថាក់ ដែលជាតំណាងក្រុមហ៊ុនពិភពពាណិជ្ជ បានចុះកិច្ចសន្យាជួលរោងចក្រតម្បាញទី ២ ពីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ( ចុះថ្ងៃទី ១២-១០-៩៣ ) ហើយក្រសួងនេះបានចេញប្រកាសប្រគល់សិទ្ធិ និង ការគ្រប់គ្រងផលិតកម្មអាជីវកម្ម លើរោងចក្រតម្បាញទី២នេះជូនក្រុមហ៊ុន ថ្ងៃទី ០២-១១-៩៣ ។ បន្ទាប់មកក្រុមហ៊ុននេះ ដែលមានលោក ថងសិទ្ធិ លីឡាប្រាក់ថាក់ ជាតំណាងបានចុះកិច្ចសន្យាសហប្រតិបត្តិការរួមមួយ (Joint venture Agreement ) ជាមួយលោក វ៉ាន់ ស៊ូអៀង គឺទាក់ទង និង ខ្លឹមសារ នៃ កិច្ចសន្យាសហប្រតិបត្តិការរួមនេះ នៅថ្ងៃទី ០៨-៦-១៩៩៧ ជាភាសាអង់គ្លេស តែម្តង ដែលបង្កើតនូវវិវាទ ថ្ងៃនេះឡើង ។

បានឃើញ ដីកាសំរេចតាមពាក្យសុំលេខ ០៣ " ឃ " ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងរបស់ឈ្មោះ វ៉ាន់ ស៊ូអៀង ដែលមានតំណាង និង ជាមេធាវីឈ្មោះ ការ សាវុត្ថ ចុះថ្ងៃទី ១៨-៥-១៩៩៨ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ហាមឃាត់ (TONGSTIT LELAPRATAK ) និង ឈ្មោះ ( LAI KIM TONG ) មិនឱ្យលក់ដូរ ផ្ទេរសិទ្ធិ បញ្ចាំ ជួល ឬ ធ្វើអំណោយ នូវទីស្នាក់ក្រុមហ៊ុនផ្ទះលេខ ៣១-៣៣ វិថីសម្តេច ចក្រីប៉ុន ផ្លូវលេខ ២០៨ សង្កាត់បឹងរាំង ខណ្ឌដូនពេញ ក្រុងភ្នំពេញ ព្រមទាំងចលនទ្រព្យ និង អចលនទ្រព្យ ដែលជាចំណែកភាគហ៊ុនរបស់ខ្លួនមាននៅក្នុង :

- ក្រុមហ៊ុន ពិភពពាណិជ្ជកម្ពុជា
- ក្រុមហ៊ុន ពិភពពាណិជ្ជធានារ៉ាប់រង
- រោងចក្រតម្បាញពិភពពាណិជ្ជ
- ក្រុមហ៊ុន ពិភពពាណិជ្ជកម្ពុជា ម៉ូទ័រចំកាត់
- ក្រុមហ៊ុន កម្ពុជាផ្សាយពាណិជ្ជកម្ម
- រោងចក្រកម្ពុជា ដេរឈើចិងចំកាត់
- ក្រុមហ៊ុន K-N-T ទីផ្សារស្រាចំកាត់
- រថយន្តតូចធំ សំរាប់ជួល

ដែលមានអាស័យដ្ឋានផ្ទះលេខ ៣១-៣៣ វិថីសម្តេចចក្រប៉ុន ផ្លូវលេខ ២០៨ សង្កាត់បឹងរាំង ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

រោងចក្រតម្បាញ ពិភពពាណិជ្ជភ្នំពេញ និង ទ្រព្យសម្បត្តិទាំងអស់ ដែលមាននៅក្នុងរោងចក្រនេះ ដែលមានទីតាំងនៅផ្លូវជាតិ ៥ ភូមិឃ្លាំងសាំង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។

រថយន្តជាកម្មសិទ្ធិរបស់ក្រុមហ៊ុន ពិភពពាណិជ្ជកម្ពុជា ម៉ូទ័រ ចំកាត់គឺ :

- Fiat Panda 1.000 = 5 Units
- Panda 4×4 = 5 Units
- Uno Super 60 = 2 Units
- Tipo sx = 2 Units

ទុកជាបណ្តោះអាសន្នសិន រង់ចាំតុលាការសំរេចដល់រឿងអង្គសេចក្តី ។

៣- បង្គាប់ឱ្យឈ្មោះ វ៉ាន់ ស៊ូអៀង ដែលមានតំណាង និង ជាមេធាវីឈ្មោះ ការ សាវុត្ថ ប្រាក់ប្រដាប់ក្តី គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹងចំនួន ១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបបង់ប្រាក់ ២០០-រៀល បូកសរុប ២.០០០រៀល ប្រាក់នេះ បានកាត់យកពីប្រាក់ ២.០០០រៀល ដោយដើមចោទបានបង់ទុកជាស្រេច ។

៤- បើគូភាគីណាមិនសុខចិត្ត នឹងដីកាសំរេចនេះ មានសិទ្ធិប្តឹងទាស់រយៈពេល ១៥ថ្ងៃ គិតពីថ្ងៃទទួលដំណឹងពីដីកាសំរេចនេះតទៅ ។

បានឃើញ ដីកាសំរេចកិច្ចការប្រញាប់លេខ ២៤ ប្រ " ក " ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០១ របស់តុលាការក្រុងភ្នំពេញ ដែលសំរេច :

១- ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី ១០-៧-២០០១ របស់ឈ្មោះ ស៊ុ ផាវ៉ាន់ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- បដិសេធសំណូមពរ គ្រប់ចំណុចរបស់លោក វ៉ាន់ ស៊ូអៀង តំណាងដោយ លោកស្រី ទិត សោភ័ណ ចោល ។

៣- សំរេចដកចេញពី ដីកាសំរេចតាមពាក្យសុំលេខ ០៣ " ឃ " ចុះថ្ងៃទី ២៨-៥-១៩៩៨ របស់តុលាការក្រុងភ្នំពេញនូវផ្ទះលេខ ៣១ ផ្លូវ ២០៨ ក្រុម ៥ សង្កាត់បឹងរាំង ខណ្ឌដូនពេញ ក្រុងភ្នំពេញ ឱ្យរួចផុតពីការហាមឃាត់ ។ ឯ ចលនទ្រព្យ និង អចលនទ្រព្យផ្សេងពីនេះ ទុកឱ្យស្ថិតនៅក្នុងការហាមឃាត់ នៃដីកាសំរេចតាមពាក្យសុំលេខ ០៣ " ឃ " ចុះថ្ងៃទី ២៨-៥-១៩៩៨ ដដែល ។

៤- បង្គាប់ឱ្យដើមចោទ បង់ប្រាក់ប្រដាប់ក្តីចំនួន ៤០០០រៀល ។ ប្រាក់នេះបានកាត់យកពីប្រាក់ប្រដាប់ក្តីរបស់ដើមចោទ ដាក់ថវិការដ្ឋ និង ចំណាយផ្សេងៗ រួចហើយ ។

៥- ដីកានេះ សំរេចសេចក្តី និង ប្រកាសជាសាធារណៈ ចំពោះមុខមេធាវី លឹម ច័ន្ទប៊ុនកែវ តំណាងដើមចោទឈ្មោះ ស៊ុ ផាវ៉ាន់ ចំពោះមុខលោកស្រី ទិត សោភ័ណ តំណាងឈ្មោះ វ៉ាន់ ស៊ូអៀង បើកផ្លូវប្តឹងឧទ្ធរណ៍រយៈពេល ២ខែ គិតពីថ្ងៃនេះតទៅ ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ១២ "ឃ" ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់តុលាការក្រុងភ្នំពេញ សំរេចចំពោះមុខគូក្តី ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹង របស់ដើមចោទ ដែលមានអ្នកទទួលសិទ្ធិមេធាវី ការ សាវុត្ថ ចុះថ្ងៃទី ១៨-៥-១៩៩៨ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទទួលពាក្យបណ្តឹងតប របស់ចុងចម្លើយ ផងសិទ្ធី លីឡាប្រាក់ថាក់ ដែលមានអ្នកទទួលសិទ្ធិមេធាវី កែវ គីមសាន ចុះថ្ងៃទី ២៨-៧-១៩៩៩ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលទាស់គតិច្បាប់ ។

៣- ទទួលស្គាល់មេធាវី ការ សាវុត្ថ ដែលជាអ្នកទទួលសិទ្ធិឱ្យដើមចោទឈ្មោះ វ៉ាន់ ស៊ូអៀង តាមលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ១៨-០៥-១៩៩៨ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៤- ទទួលស្គាល់មេធាវី កែវ គីមសាន្ត ដែលជាអ្នកទទួលសិទ្ធិពីចុងចម្លើយឈ្មោះ ផងសិទ្ធី - លីឡាប្រាក់ថាក់ តាមលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ២៤-៦-១៩៩៨ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៥- ឱ្យមោឃៈភាពកិច្ចសន្យាធ្វើសហការអាជីវកម្ម និង គ្រប់គ្រងរវាងក្រុមហ៊ុនពិភពពាណិជ្ជ ផងសិទ្ធី លីឡាប្រាក់ថាក់ និង វ៉ាន់ ស៊ូអៀង ចុះថ្ងៃទី ០៨-៦-១៩៩៧ ចោលចាប់ពីពេលនេះតទៅ ។

៦- បង្គាប់ឱ្យចុងចម្លើយឈ្មោះ ផងសិទ្ធី លីឡាប្រាក់ថាក់ ដែលមានតំណាង និង ជាមេធាវីឈ្មោះ កែវ គីមសាន្ត សងប្រាក់ចំនួន ៩៧០០៧$ ( ប្រាំបួនម៉ឺនប្រាំពីរពាន់ ប្រាំពីរដុល្លាអាមេរិក ) ប្រាក់រៀលចំនួន ១.៦៧៣.០០០រៀល ( មួយរយហុកសិបប្រាំពីរម៉ឺន បីពាន់រៀល ) ការប្រាក់ចំនួន៥% ក្នុងមួយ

ឆ្នាំ គិតចាប់ពីថ្ងៃទី ០៨-៦-១៩៩៧ នៃ ចំនួនប្រាក់ដើមទាំងអស់រហូតដល់ថ្ងៃសងគ្រប់ចំនួន និង សងជំងឺចិត្ត ចំនួន ៤០.០០០$ ( បួនម៉ឺនដុល្លារអាមេរិក ) ទៅឱ្យដើមចោទឈ្មោះ វ៉ាន់ ស៊ូអៀង វិញ ចាប់តាំងពីសាលក្រមចូលជាស្ថាពរ ។

បើឈ្មោះនេះ គ្មានប្រាក់សងត្រូវរឹបអូសទ្រព្យសម្បត្តិ ដែលមាននៅក្នុងដីកាសំរេចតាមពាក្យសុំលេខ ០៣ ( ឃ ) ចុះថ្ងៃទី ២៨-៥-១៩៩៨ លក់ឡាយឡុងធានាសំណង បើពុំគ្រប់ទើបត្រូវដាក់គុកបង្ខំដល់រូបកាយចំនួន ៨ខែ តាមមាត្រា ១៣៣ នៃ ច្បាប់ស្ដីពីការអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៧- រឹបអូសប្រាក់ប្រដាប់ក្ដី គឺពន្ធចុះបញ្ជីក្ដី និង ពន្ធហ្វីងចំនួន ១៨០០រៀល វង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ២០០៛ វង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០៛ សរុប ៧.០០០ ៛ ពីចុងចម្លើយឈ្មោះ ថងសិទ្ធី លីឡាប្រាក់ថាក់ មានតំណាងឈ្មោះ កែវ គឹមសាន្ត បានបង់ទុករួចជាស្រេច ។

៨- បង្គាប់ឱ្យ ថងសិទ្ធី លីឡាប្រាក់ថាក់ ដែលមានតំណាងឈ្មោះ កែវ គឹមសាន្ត បង់ប្រាក់ប្រដាប់ក្ដី គឺ ពន្ធចុះបញ្ជីក្ដី និង ពន្ធហ្វីងចំនួន ១៨០០រៀល វង្វាន់អ្នកប្រគល់ដីកាកោះចំនួន ៥.០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០៛ ដែលដើមចោទបានបង់ទុករួចជាស្រេច ។

កាលបើហួសឧទ្ធរណ៍ បង្គាប់ឱ្យចុងចម្លើយសងប្រាក់ ៧០០០៛ នេះ ទៅឱ្យដើមចោទវិញ ។

បង្គាប់ឱ្យឈ្មោះ ថងសិទ្ធី លីឡាប្រាក់ថាក់ ដែលមានតំណាងឈ្មោះ កែវ គឹមសាន បង់ពន្ធសមាមាត្រមួយភាគរយលើប្រាក់ដើមចំនួន ៩៧.០០៧$ ប្រាក់រៀលចំនួន ១.៦៣៧០០០រៀល និងការប្រាក់ ៥% ក្នុងមួយឆ្នាំ ព្រមទាំងជំងឺចិត្តចំនួន ៤០០០០$ ។ ប្រាក់នេះត្រូវដាក់ចូលថវិការដ្ឋចំនួន ៨០% និងបានជាវង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០% ។

៩- សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខគូភាគី សំរេចបើកផ្លូវប្ដឹងឧទ្ធរណ៍កំណត់ ២ខែ គិតចាប់តាំងពីថ្ងៃនេះតទៅ ។

បានឃើញ បណ្ដឹងឧទ្ធរណ៍ លេខ ១៥ " ឃ " ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩៩ របស់មេធាវី លោកស្រី កែវ គឹមសាន ប្ដឹងមិនសុខចិត្ត នឹង សាលក្រមលេខ ១២ " ឃ " ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់តុលាការក្រុងភ្នំពេញ លើគ្រប់ចំណុចសេចក្ដីវិនិច្ឆ័យទាំងមូល ។

បានឃើញ សាលដីការដ្ឋប្បវេណី លេខ ១០ " ឈ " ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ សំរេចចំពោះមុខមេធាវី តំណាងឱ្យដើមចោទលោកជូ ចាន់ធីរ៉ា កំបាំងមុខមេធាវីតំណាងឱ្យចុងចម្លើយលោកស្រី កែវ គឹមសាន ដែលមានខ្លឹមសារ នៃ សេចក្ដី សំរេចដូចតទៅ :

១- ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៥-១០-៩៩ របស់ឈ្មោះ កែវ គឹមសាន ជាមេធាវី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២- តំកល់សាលក្រមរដ្ឋប្បវេណីលេខ ១២ " ឃ " ចុះថ្ងៃទី ២៣-០៩-៩៩ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ។

៣- សំរេចកាត់យកប្រាក់ប្រដាប់ក្ដីចំនួន ១៣.០០០រៀល ដែលដើមបណ្ដឹងឧទ្ធរណ៍បានបង់ទុករួចហើយ គឺពន្ធចុះបញ្ជីក្ដី និង ពន្ធហ្វីងចំនួន ២៥៥០ រៀល វង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ៤៥០ រៀល

រង្វាន់អ្នកប្រគល់ដីកាកោះចំនួន ៥.០០០រៀល និង ចំណាយលើអាជ្ញាធរ តុលាការចំនួន ៥.០០០រៀល ។

៤- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ២៤-៨-២០០០ ចំពោះមុខមេធាវីតំណាងឱ្យដើមចោទលោកជូ ចាន់ធីរ៉ា កំបាំងមុខមេធាវីតំណាងឱ្យចុងចម្លើយលោកស្រីកែវ គឹមសាន។ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្តឹងទាស់លេខ៩៧ ចុះថ្ងៃទី០៦ ខែ វិច្ឆិកា ឆ្នាំ ២០០០ របស់លោក ផងសិទ្ធ- លីឡាប្រាក់ថាក់ ប្តឹងមិនសុខចិត្ត នឹងសាលដីកា រដ្ឋប្បវេណី លេខ ១០ " ឈ " ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ លើត្រង់ចំណុច នៃ សេចក្តីសំរេចទាំងមូល ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ ៤៩ " ឈ " ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ សំរេចចំពោះមុខមេធាវីតំណាងឱ្យដើមចោទលោក ជូ ចាន់ធីរ៉ា និង មេធាវីតំណាង ឱ្យចុងចម្លើយអ្នកស្រី កែវ គឹមសាន ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងទាស់របស់មេធាវី កែវ គឹមសាន ចុះថ្ងៃទី ១៦-១១-២០០០ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីកាលេខ ១០ " ឈ " ចុះថ្ងៃទី ២៤-៨-២០០០ របស់សាលាឧទ្ធរណ៍ ទុកជាបានការទាំងមូល ។

៣- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខមេធាវីតំណាងឱ្យដើមចោទលោក ជូ ចាន់ធីរ៉ា និង មេធាវីតំណាងឱ្យចុងចម្លើយ អ្នកស្រី កែវ គឹមសាន ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលេខ ២៣ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០០ របស់លោកស្រី កែវ គឹមសាន ប្តឹងមិនសុខចិត្ត នឹងសាលដីកា រដ្ឋប្បវេណី លេខ ៤៩ " ឈ " ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ លើត្រង់ចំណុច នៃ សេចក្តីសំរេចទាំងមូល ។

បានឃើញ សារណាការពារ ចុះថ្ងៃទី ១៤-០៥-២០០១ របស់លោកស្រី កែវ គឹមសាន

បានឃើញ សារណាតប ចុះថ្ងៃទី ២៨-០៦-២០០១ របស់ លោក វ៉ាន់ ស៊ូអៀង

បានស្តាប់ របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ថា :

សាលដីកា រដ្ឋប្បវេណីលេខ៤៩ " ឈ " ចុះថ្ងៃទី ២៨-១១-២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សំរេច ។

ក្រឡាបញ្ជីអានសារណារបស់លោក ផងសិទ្ធ លីឡាប្រាក់ថាក់

ក្រឡាបញ្ជីអានសារណារបស់លោក វ៉ាន់ ស៊ូអៀង

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី លោកស្រី កែវ គឹមសាន បញ្ជាក់ថា :

កាលពីថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៩៧ ក្រុមហ៊ុនពិភពពាណិជ្ជកម្ពុជា តំណាងដោយ

លោក ថងសិទ្ធី លីឡាប្រាក់ថាក់ បានព្រមព្រៀងជាមួយលោក វ៉ាន់ ស៊ូអៀង ចុះកិច្ចសន្យាធ្វើសហការអាជីវកម្ម និង គ្រប់គ្រងក្រោយកិច្ចសន្យានោះរួចមក ។ លុះថ្ងៃទី ១១-១២-៩៧ ស្រាប់តែក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ចេញប្រកាសដកហូតទីតាំងពីភាគីកូនក្តីនាងខ្ញុំវិញ ហើយនៅថ្ងៃទី ១៨-៥-៩៨ ឈ្មោះ វ៉ាន់ ស៊ូអៀង បែរជាមកប្តឹងភាគីកូនក្តីនាងខ្ញុំ ដោយពុំគោរពកិច្ចសន្យា ព្រោះតាមកិច្ចសន្យាចុះថ្ងៃទី ៨-៦-៩៧ ត្រង់ចំណុចទី ១, ៤, ៦ បានបញ្ជាក់យ៉ាងច្បាស់ហើយថា ទោះបីជារដ្ឋាភិបាលសំរេចដកហូតសិទ្ធិគ្រប់គ្រងរោងចក្រ ដោយប្រការនោះក៏ដោយ ក៏មិនផ្តល់សិទ្ធិឱ្យភាគី " ខ " ទាមទារការខាតបង់អ្វីពីភាគី " ក " ឡើយ ។ ដូច្នេះបើមានការខាតបង់ដោយប្រការណាមួយ ក្រោយពីចុះកិច្ចសន្យាគឺ គូភាគី ត្រូវទទួលខុសត្រូវរួមគ្នាពុំមែន ត្រូវឱ្យភាគីម្ខាងប្តឹងទាមទារពីភាគីម្ខាងទៀតនោះទេ ។

ហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចបដិសេធសាលដីកាលេខ ១០ " ឈ " ចុះថ្ងៃទី ២៤-៨-២០០០ របស់សាលាឧទ្ធរណ៍ចោលទាំងស្រុង ។ បដិសេធដីកាសំរេចតាមពាក្យសុំលេខ ០៣ " ឃ " ចុះថ្ងៃទី ២៨-៥-១៩៩៨ របស់តុលាការក្រុងភ្នំពេញ ទុកជាមោឃៈត្រង់ចំណុចឃាត់ផ្ទះលេខ ៣១ និង ៣៣ វិថីសម្តេចក្រឹប៉ុន សង្កាត់បឹងរាំង ខណ្ឌដូនពេញ ហើយប្រគល់ផ្ទះលេខ ៣១ និង ៣៣ ទៅឱ្យឈ្មោះ ស៊ុ ដាវ៉ាន់ វិញ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីលោក ជូ ចាន់ធារ៉ា បញ្ជាក់ថា :

នៅថ្ងៃទី៨-៦-៩៧ កូនក្តីរបស់ខ្ញុំលោកវ៉ាន់ ស៊ូអៀង និងលោក ថងសិទ្ធី លីឡាប្រាក់ថាក់ តំណាងក្រុមហ៊ុនពិភពពាណិជ្ជបានព្រមព្រៀងគ្នាចុះកិច្ចសន្យា សហការអាជីវកម្ម ដែលជាកិច្ចសន្យាជួលទីតាំងពីក្រុមហ៊ុនពិភពពាណិជ្ជ មានរយៈពេលកំណត់ច្បាស់លាស់៥ឆ្នាំ និង កំរៃ ៦០.០០០ $ ក្នុងមួយឆ្នាំ ដូចមានកំណត់ក្នុងមាត្រា ៨ និង ៤ នៃកិច្ចសន្យា ។ ចាប់តាំងពីថ្ងៃទី ៨-៦-៩៧ ដែលបានព្រមព្រៀងគ្នាមកបានអនុវត្តកាតព្វកិច្ច ដូចជា :

- ប្រគល់ប្រាក់កក់គ្រប់ចំនួន ៦០.០០០$ គឺ នៅថ្ងៃទី ៨-៦-៩៧ ចំនួន ៣០.០០០$ និង នៅថ្ងៃទី ២៥-៧-៩៧ ចំនួន ៣០.០០០$ ។
- ប្រគល់ប្រាក់ថ្លៃជួសជុលពីមុនចំនួន ១២.៥០០$ គឺនៅថ្ងៃទី ២២-១០-៩៧ ចំនួន ៨.០០០$ និង នៅថ្ងៃទី ៨-១២-៩៧ ចំនួន ៤៥០០ $ ទៅឱ្យក្រុមហ៊ុនពិភពពាណិជ្ជ ។
- បានចំណាយប្រាក់ជួសជុល កែលំអររោងចក្រឡើងវិញ អស់ចំនួន ១៩.៥០៧$ ។
- បង់ប្រាក់ឈ្នួលប្រចាំខែ ដំបូង ៥.០០០ $ ។
- បង់ថ្លៃទឹកអគ្គីសនី ១៦៧៣.០០០ រៀល ។ សរុបចំណាយទាំងអស់ ៩៧០០៧ $ និង ១៦៧៣.០០០រៀល ។

សូមក្រុមប្រឹក្សា ជំនុំជំរះ តម្កល់សាលដីការដ្ឋប្បវេណីលេខ ៤៩ " ឈ " ចុះថ្ងៃទី ២៨-១១-២០០០ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្ដាប់សារណារបស់គូភាគីនិង សេចក្ដីសន្និដ្ឋានរបស់មេធាវីនៃគូភាគី
- ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ២៣ ចុះថ្ងៃទី ២២-០១-២០០១ របស់អ្នកស្រី កែវ គីមសាន មេធាវីរបស់ចុងចម្លើយ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះ បានតាមមាត្រា១៤ នៃ ច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្ដី ។

- យល់ឃើញថា ការដែលអ្នកស្រី កែវ គីមសាន លើកឡើងក្នុងសារណា ចុះថ្ងៃទី ១៤-៥-២០០១ ថា តាមប្រការ ១៤-៦ នៃ កិច្ចសន្យាសហការអាជីវកម្ម និង គ្រប់គ្រង ចុះថ្ងៃទី ៨-៦-៩៧ បញ្ជាក់ថា " ទោះបីរដ្ឋាភិបាលសំរេចដកហូតសិទ្ធិគ្រប់គ្រង រោងចក្រដោយប្រការនោះក៏ដោយ ក៏មិនផ្ដល់សិទ្ធិឱ្យភាគី " ខ " ទាមទារការខាតបង់អ្វីពីភាគី " ក " បានឡើយ ហើយការខាតបង់ណាមួយក្រោយពីចុះកិច្ចសន្យា គូភាគីត្រូវទទួលខុសត្រូវរួមគ្នា ពុំមែនឱ្យភាគីម្ខាងប្ដឹងទាមទារពីភាគីម្ខាងទៀតនោះ គឺជាការពុំត្រឹមត្រូវទេ ពីព្រោះចុងចម្លើយបានដំណាក់ប្រាក់ថ្លៃឈ្នួលរោងចក្ររបស់ក្រសួងឧស្សាហកម្មរ៉ែនិង ថាមពល តាំងពីមុនចុះកិច្ចសន្យាថ្ងៃទី ៨-៦-៩៧ ដោយដើមចោទពុំបានដឹង ដែលជាមូលហេតុធ្វើឱ្យរដ្ឋសំរេចដកហូតយកទីតាំងនេះវិញ ។ ដូច្នេះដើមចោទពុំអាចទទួលខុសត្រូវលើការខាតបង់តាមប្រការ ១៤ , ៦ នៃកិច្ចសន្យាសហការអាជីវកម្ម និង គ្រប់គ្រងបានទេ ពីព្រោះការដកហូតទីតាំងនេះ មិនមែនបណ្ដាលមកពីការកកំរៃ នៃការ ជួលអចលនវត្ថុទេ ។

- យល់ឃើញថា ការដែលតុលាការថ្នាក់ក្រោមសំរេចដាក់គុកបង្ខំលើរូបកាយលោកថេងសិទ្ធី-លីឡាប្រាក់ថាក់ ដែលជានីតិបុគ្គលនោះ ជាការពុំត្រឹមត្រូវទេ ប៉ុន្តែដោយរឿងនេះ ជារឿងអង្គច្បាប់សុទ្ធសាធ ដូច្នេះ តុលាការកំពូល គប្បីសំរេច ទុកជាមោឃៈ ដោយឥតបង្វិល ។

- យល់ឃើញថា ការដែលមេធាវីចុងចម្លើយ ក៏ដូចជាសារណារបស់ចុងចម្លើយដែរ ដែលលើកឡើងថា ការឱ្យជម្ងឺចិត្ត ៤ម៉ឺនដុល្លារអាមេរិក មានចំនួនច្រើនហួសនោះ តុលាការកំពូល ដែលជំនុំជំរះពេលនេះ តែលើអង្គច្បាប់ពុំមានសមត្ថកិច្ចសំរេចបានឡើយ ពីព្រោះជាសមត្ថកិច្ចរបស់តុលាការអង្គសេចក្ដី ។

- យល់ឃើញថា ពាក្យបណ្ដឹង ចុះថ្ងៃទី ១២-៦-២០០១ របស់លោក លឹម ច័ន្ទប៊ុនកែវ ជាមេធាវីរបស់អ្នកស្រី ស៊ុ ដាវ៉ាន់ ដែលសុំចូលជាតតីយជននោះ តុលាការកំពូល ពុំមានសមត្ថកិច្ចជំនុំជំរះបានឡើយ ពីព្រោះតុលាការកំពូល ជំនុំជំរះលើកទី ១ តែលើអង្គច្បាប់ មិនពិនិត្យលើអង្គហេតុថ្មីទេ ។

- យល់ឃើញថា គូភាគី បានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះ មានតែមេធាវី នៃ គូភាគី ដែលបានមកចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះ កំបាំងមុខចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៤៩ " ឈ " ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ លើកលែងតែចំណុចដាក់គុកបង្ខំលើរូបកាយ ។

## ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តីកំបាំងមុខគូក្តី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១- ទទួលបណ្តឹងសាទុក្ខលេខ ២៣ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១ របស់អ្នកស្រី កែវ គឹមសាន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុស នឹង គតិច្បាប់ខ្លះ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ៤៩ " ឈ " ចុះថ្ងៃទី ២៨ ខែវិច្ឆិកាឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែចំណុចដាក់គុកបង្ខំលើរូបកាយ ដែលត្រូវទុកជាមោឃៈដោយឥតបង្អិល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលលោក វ៉ាន់ ស៊ូអៀង បានបង់ជូនរួចហើយគឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹងចំនួន ៤០០០រៀល ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់,
- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវឱ្យចុងចម្លើយសងប្រាក់ ១៩.០០០រៀល នេះ ទៅដើមចោទវិញ ។

បង្គាប់ឱ្យចុងចម្លើយបង់ពន្ធសមាមាត្រ តាមការកំណត់របស់តុលាការក្រុងភ្នំពេញ ។

៤- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០០១ ។